クメール（カンボジア）語

# ជំនួយជាពហុភាសា ក្នុងការចាក់វ៉ាក់សាំង ដោយ FRESC

FRESC(មជ្ឈមណ្ឌលជំនួយសម្រាប់ការស្នាក់នៅរបស់ជនបរទេស) ជួយក្នុងការចាក់វ៉ាក់សាំងការពារ COVID-19 តាមស្ថាប័នពេទ្យដែលសហប្រតិបត្តិការនៅតូក្យូ ណាហ្គូយ៉ា អូសាកា ជាពហុភាសា !

ចំពោះអ្នកដែលមានប័ណ្ណចាក់វ៉ាក់សាំង សូមមើលខាងក្រោមនេះ↓

**កន្លែងទំនាក់ទំនងដើម្បីកក់ពេលវេលាចាក់វ៉ាក់សាំងនឹង FRESC**

Tel : 03-4332-2601

ម៉ោងទទួល : 9:00～17:00 (ទទួលតែនៅថ្ងៃធម្មតា)

ភាសាដែលអាចឆ្លើយតបបាន : ជប៉ុន, អង់គ្លេស, ចិន, កូរេ, ព័រទុយហ្គាល់, អេស្ប៉ាញ, ថៃ, វៀតណាម, ហ្វីលីពីន, ខ្មែរ, ណេប៉ាល់, ឥណ្ឌូណេស៊ី, មីយ៉ាន់ម៉ា, ម៉ុងហ្គោល, បារាំង, ស៊ីងហាឡា, អ៊ូលឌូ, បិនហ្គាល់

គេហទំព័រ :

https://www.moj.go.jp/isa/support/portal/vaccine_covid19.html

ចំពោះអ្នកដែលអត់មានប័ណ្ណចាក់វ៉ាក់សាំង សូមមើលទំព័របន្ទាប់

# ចំពោះអ្នកដែលអត់មានប័ណ្ណចាក់វ៉ាក់សាំង សូមមើលខាងក្រោមនេះ↓

## <ឧទាហរណ៍នៃលំហូររហូតដល់ការចាក់វ៉ាក់សាំង>

※នេះគឺជាលំហូរនៃការចាក់វ៉ាក់សាំង ទៅតាមអ្នកដែលជាមុខសញ្ញានីមួយៗ↓

ស្ដីពីការសុំឱ្យគេចេញប័ណ្ណចាក់វ៉ាក់សាំង សូមពិគ្រោះនឹងរដ្ឋបាលស្រុកឃុំភូមិ

①របស់ដែលបញ្ជាក់ស្ថានភាពស្នាក់នៅ (ឯកសារបញ្ជាក់ការបង់ថ្លៃទឹកភ្លើងហ្គាស់ជាដើម)
②សូមយកឯកសារបញ្ជាក់អត្តសញ្ញាណ (លិខិតឆ្លងដែន ជាអាទិ៍) ទៅពិគ្រោះអំពីការសុំប័ណ្ណចាក់វ៉ាក់សាំងនៅរដ្ឋបាលមូលដ្ឋាន

※ឯកសារចាំបាច់ដើម្បីសុំប័ណ្ណចាក់វ៉ាក់សាំង ខុសៗគ្នាទៅតាមរដ្ឋបាលមូលដ្ឋាន ដូច្នេះសូមទៅពិគ្រោះតាមរដ្ឋបាលមូលដ្ឋាន រួមទាំងករណីដែលមានការពិបាកនឹងដាក់ឯកសារទាំងនេះ។
※បើសិនជាមានបញ្ហា សូមពិគ្រោះនឹងកន្លែងពិគ្រោះរបស់ FRESC។

↓

ទទួលប័ណ្ណចាក់វ៉ាក់សាំងពីអង្គភាពរដ្ឋបាលមូលដ្ឋាននីមួយៗ

↓



លោកអ្នកអាចជ្រើសរើសកន្លែងដែលចង់ទៅចាក់វ៉ាក់សាំងបាន។

អ្នកដែលចង់ចាក់នៅអង្គភាពរដ្ឋបាលមូលដ្ឋានលំនៅដ្ឋានខ្លួន
សូមកក់នៅមជ្ឈមណ្ឌលចាក់ខ្នាតធំជាដើម នៃស្រុកឃុំភូមិ
※វិធីកក់ គឺខុសៗគ្នាទៅតាមស្រុកឃុំភូមិ ឬកន្លែងចាក់នីមួយៗ ដូច្នេះសូមបញ្ជាក់ឱ្យច្បាស់លាស់។

↓

ចាក់វ៉ាក់សាំងនៅមជ្ឈមណ្ឌលចាក់វ៉ាក់សាំងខ្នាតធំនៃស្រុកឃុំភូមិ

**អ្នកដែលចង់ចាក់វ៉ាក់សាំងនៅកន្លែងចាក់វ៉ាក់សាំងនៃស្ថាប័នពេទ្យសហប្រតិបត្តិការនឹង FRESC (តូក្យូ ណាហ្គូយ៉ា អូសាកា) សូម**
**កក់តាមលេខទូរស័ព្ទសម្រាប់កក់របស់ FRESC**
※Tel 03-4332-2601
លំអិត សូមមើលគេហទំព័រនៅទំព័រមុន។



↓

**ចាក់នៅកន្លែងចាក់វ៉ាក់សាំងនីមួយៗ**

អ្នកដែលជាមុខសញ្ញានៃការជួយរបស់យើងខ្ញុំមានដូចតទៅ៖
- អ្នកដែលស្នាក់នៅរយៈពេលមធ្យមនិងវែង
- អ្នកដែលស្នាក់នៅរយៈពេលខ្លី តែមានការពិបាកនឹងត្រឡប់ទៅវិញ (អ្នកដែលស្នាក់នៅជាប់នពី 3 ខែឡើងទៅ)
- អ្នកដែលកំពុងជាប់នីតិវិធីដេញចេញដោយបង្ខំ

បើសិនជាមិនដឹងអំពីរបៀបសុំប័ណ្ណចាក់វ៉ាក់សាំងនៅកន្លែងមានលំនៅដ្ឋានលោកអ្នក សូមទាក់ទងទៅ↓

**កន្លែងជួយណែនាំនៃមជ្ឈមណ្ឌលជំនួយសម្រាប់ការស្នាក់នៅរបស់ជនបរទេស FRESC**
Tel ：0120-76-2029 (លេខមិនយកថ្លៃទេ)
ម៉ោងទទួលនិងភាសាដែលអាចឆ្លើយតបបានមានដូចក្នុង “កន្លែងទំនាក់ទំនងដើម្បីកក់ពេលវេលាចាក់វ៉ាក់សាំងនឹង FRESC” ដែរ